01057276

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារ/No: D208/1/1/2

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី
ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ១៦)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Rowan DOWNING
ចៅក្រម នីយ ធុល
ចៅក្រម Chang-Ho CHUNG
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / 01 / 2015
ម៉ោង (Time/Heure): 11:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

---

សាធារណៈ (សំណៅកោសលុប)

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងដីកាសម្រេចបដិសេធសំណើរបស់គាត់ ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣**

---

**សហព្រះរាជអាជ្ញា៖**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តីម្ចាស់បណ្តឹងឧទ្ធរណ៍៖**

មុំ លុយ
Richard ROGERS
Göran SLUITER

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ទី ស្រីនណា
វ៉េន ពៅ
ស៊ិន សុវ៉ន

Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
François GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE
Emmanuel JACOMY

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់ ស្នើសុំព័ត៌មាន ពាក់ព័ន្ធនឹងកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣" ដែលបានដាក់ជាភាសាអង់គ្លេស នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ និងជាភាសាខ្មែរ នៅថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១៤ ( "ម្ចាស់បណ្ដឹងឧទ្ធរណ៍" និង "បណ្ដឹងឧទ្ធរណ៍")[1]។

## I. សេចក្ដីផ្ដើម

### ក. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទីនាពេលនោះបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទៅសហចៅក្រមស៊ើបអង្កេត ដោយបើក និងចាប់ផ្ដើមជាផ្លូវការនូវកិច្ចស៊ើបសួរទៅលើឧក្រិដ្ឋកម្មនានាដែលម្ចាស់បណ្ដឹងឧទ្ធរណ៍ រួមនឹងបុគ្គលផ្សេងៗទៀត ត្រូវបានចោទប្រកាន់ថាជាអ្នកទទួលខុសត្រូវ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ")[2]។ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១[3] និង ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤[4]។

២. នៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៤ ដល់ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាសម្រេចចំនួន បួន ដោយច្រានចោលសំណើនានាដែលបានដាក់ដោយម្ចាស់បណ្ដឹងឧទ្ធរណ៍ ដោយគាត់បានកត់សម្គាល់ថា គាត់ និងសហចៅក្រមស៊ើបអង្កេតជាតិបានចុះបញ្ជីនៃករណីខ្វែងយោបល់គ្នាមួយនៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣ ("សេចក្ដី

[1] ឯកសារ D208/1/1/1។

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។ សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទី អំពីការដាក់ឯកសារស្ដីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។

[3] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ D65។

[4] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D191។

សម្រេចចំនួនបួន” និង “ករណីខ្វែងយោបល់គ្នា នៅខែ មេសា ឆ្នាំ ២០១៣” ជាបន្តបន្ទាប់គ្នា)[5]។ ដីកាសម្រេចទាំងនេះពាក់ព័ន្ធនឹងសំណើសុំមោឃភាពកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤ ដោយសំអាងថា ពុំមានយុត្តាធិការបុគ្គល[6] សំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបី អនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង[7] និងសំណើមួយសុំឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាឡើងវិញទៅលើដីកាសម្រេចពីមុនរបស់ខ្លួន ដែលបានបដិសេធមិនឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍ចូលពិនិត្យមើលសំណុំរឿង និងសិទ្ធិចូលរួមក្នុងកិច្ចស៊ើបសួរ[8]។

៣. នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់ញត្តិមួយដោយស្នើសុំសហចៅក្រមស៊ើបអង្កេតឱ្យផ្តល់ព័ត៌មានពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នានៅខែ មេសា ឆ្នាំ ២០១៣ ជាពិសេសគឺព័ត៌មានអំពី **ក.** អង្គហេតុ និងហេតុផលនានានៃការខ្វែងយោបល់គ្នា **ខ.** វិសាលភាពនៃការខ្វែងយោបល់គ្នា និង **គ.** ការឆ្លើយតបនានារបស់សហចៅក្រមស៊ើបអង្កេតជាតិ រួមទាំងថាតើគាត់ធ្លាប់បដិសេធមិនចូលរួម ក្នុងការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងការដាក់ឯកសារនានាក្នុងសំណុំរឿង

---

[5] ដីកាសម្រេចបឋមលើសំណើពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបដិសេធមិនអនុញ្ញាតឱ្យ [redacted] ចូលពិនិត្យមើលសំណុំរឿង ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D121/4/5 (“ដីកាសម្រេចបឋមលើសំណើពិចារណាឡើងវិញ”)។ ដីកាសម្រេចលើសំណើពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ក្រុមមេធាវីការពារក្តី [redacted] ចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងការស៊ើបអង្កេត ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D121/4/6 (“ដីកាសម្រេចលើសំណើពិចារណាឡើងវិញ”)។ ដីកាសម្រេចលើញត្តិរបស់ [redacted] ស្នើសុំមោឃភាពកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D185/1 (“ដីកាសម្រេចលើសំណើសុំមោឃភាព”)។ ដីកាសម្រេចលើសំណើរបស់ [redacted] សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D190 (“ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ”)។

[6] ដីកាសម្រេចលើសំណើសុំមោឃភាព *ដោយច្រានចោល*ញត្តិរបស់ [redacted] ស្នើសុំមោឃភាពកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D185។

[7] ដីកាសម្រេចលើសំណើសុំមោឃភាព *ដោយច្រានចោល* សំណើលើកទី១ របស់ [redacted] សុំបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D187។ សំណើលើកទី២ របស់ [redacted] សុំបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D188។ សំណើលើកទី៣២ របស់ [redacted] សុំបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D189។

[8] ដីកាសម្រេចបឋមលើសំណើពិចារណាឡើងវិញ *និង* ដីកាសម្រេចលើសំណើពិចារណាឡើងវិញ *ដោយច្រានចោល* ញត្តិរបស់ [redacted] សុំពិចារណាឡើងវិញទៅលើដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់មេធាវីការពារក្តី [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D121/4/4។

01057279



០០៤ ឬទេ (“ញត្តិស្នើសុំព័ត៌មាន”)[9]។

៤. នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា ក្នុងនាមជាជនសង្ស័យក្នុងសំណុំរឿង ០០៤ ម្ចាស់បណ្តឹងឧទ្ធរណ៍មានផលប្រយោជន៍តាមផ្លូវច្បាប់ ក្នុងការនាំយកញត្តិស្នើសុំព័ត៌មាននៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី ហើយហេតុនេះ ញត្តិនេះអាចទទួលយកបាន អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង[10]។ ទោះយ៉ាងណាក្តី គាត់បានបដិសេធមិនទទួលយកញត្តិនេះដោយផ្អែកលើខ្លឹមសារ និងសំអាងលើមូលដ្ឋានថា ក. ការលើកយោងទៅលើករណីខ្វែងយោបល់គ្នា នៅខែមេសា ឆ្នាំ ២០១៣ នៅក្នុងដីកាសម្រេចទាំងបួន មិនបង្ហាញថាពុំមានកិច្ចសហការរបស់សហចៅក្រមស៊ើបអង្កេតឡើយ ដោយសារថា “ការខ្វែងយោបល់លើបញ្ហាជាក់លាក់ណាមួយ អាចអនុវត្តទៅលើសេចក្តីសម្រេចនាពេលអនាគតដែលពាក់ព័ន្ធនឹងបញ្ហាដូចគ្នា ឬបញ្ហាពាក់ព័ន្ធ”[11] ខ. ម្ចាស់បណ្តឹងឧទ្ធរណ៍ “មិនបានបង្ហាញថា ហេតុអ្វីបានជាព័ត៌មានជាក់លាក់អំពីការខ្វែងយោបល់គ្នាដែលបានកើតឡើង [រវាងសហចៅក្រមស៊ើបអង្កេត] គឺមានភាពចាំបាច់ដើម្បីកំណត់ថា តើសិទ្ធិ [របស់ម្ចាស់បណ្តឹងឧទ្ធរណ៍]ក្នុងការទទួលបានភាពស្មើគ្នា ត្រូវបានគោរពឬអត់ទេ”[12] និង គ. ការខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេតគឺជាបញ្ហាសម្ងាត់[13] (“ដីកាសម្រេចដែលរងការជំទាស់”)។

## ខ. បណ្តឹងឧទ្ធរណ៍

៥. នៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៤ ម្ចាស់បណ្តឹងឧទ្ធរណ៍បានផ្តល់សេចក្តីជូនដំណឹងអំពីការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចដែលរងការជំទាស់នេះ ហើយគាត់បានដាក់បណ្តឹងឧទ្ធរណ៍ជាភាសាអង់គ្លេសនៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ និង ជាភាសាខ្មែរ នៅថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១៤។ ម្ចាស់បណ្តឹងឧទ្ធរណ៍លើកទឡ្ហីករណ៍ថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបានអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង បន្ទាប់ពីទទួលបានការបញ្ជាក់បំភ្លឺពីការខ្វែងយោបល់គ្នាដែលមាន

[9] ញត្តិស្នើសុំព័ត៌មានអំពីកំណត់ហេតុនៃករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D208។

[10] ដីកាសម្រេចលើញត្តិរបស់ជនសង្ស័យស្នើសុំព័ត៌មានអំពីកំណត់ហេតុនៃករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ D208/1 កថាខណ្ឌ ៧។

[11] *ដូចយោងខាងលើ* កថាខណ្ឌ ៨។

[12] *ដូចយោងខាងលើ* កថាខណ្ឌ ៩។

[13] *ដូចយោងខាងលើ* កថាខណ្ឌ ១០។

01057280



ចែងក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុង ហើយព័ត៌មានអំពីករណីខ្វែងយោបល់គ្នា នៅខែ មេសា ឆ្នាំ ២០១៣ ដែលទំនងជាមានវិសាលភាពទូលំទូលាយ ជាព័ត៌មានចាំបាច់ដើម្បីធានាដល់សិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានការកាត់ក្តីដោយតុលាការ ដែលត្រូវបានបង្កើតឡើងដោយច្បាប់ សិទ្ធិទទួលការការពារក្តីដោយមានប្រសិទ្ធភាព និងសមភាពចំពោះមុខច្បាប់[14]។ បើតាមខ្លឹមសារ ម្ចាស់បណ្តឹងឧទ្ធរណ៍លើកទឡ្ហីករណ៍ថា ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើវិធាន ៧២ នៃវិធានផ្ទៃក្នុងដែលនឹងអនុញ្ញាតឱ្យចុះបញ្ជីនូវករណីខ្វែងយោបល់គ្នាទូលំទូលាយ ជាជាងករណីខ្វែងយោបល់គ្នាជាក់លាក់ ពាក់ព័ន្ធនឹងបញ្ហាដោយឡែកនីមួយៗនៅចំពោះមុខពួកគាត់ គឺជាការបកស្រាយមិនត្រឹមត្រូវឡើយ ដោយសារមិនបានពិចារណាដល់កាតព្វកិច្ចផ្លូវច្បាប់របស់សហចៅក្រមស៊ើបអង្កេត ក្នុងការសហការគ្នា និងការពិភាក្សាសម្រេចទៅលើសារណានានាដែលបានដាក់ដោយភាគី ឬដោយអ្នកចូលរួមក្នុងកិច្ចដំណើរការនីតិវិធីទេ[15]។ មេធាវីការពារក្តីលើកទឡ្ហីករណ៍ថា ការខ្វែងយោបល់គ្នាមិនអាចទុកចោលមិនដោះស្រាយជារៀងរហូត ឬរក្សាជាការសម្ងាត់សម្រាប់ជនសង្ស័យបានទេ ពីព្រោះថា ការធ្វើដូច្នេះ ជនសង្ស័យមិនអាចជំទាស់នឹងការរំលោភបំពានជាសក្តានុពលទៅលើសិទ្ធិរបស់ពួកគេតាមវិធីផ្សេងទៀត និងពុំមានដំណោះស្រាយតាមផ្លូវច្បាប់ឡើយ[16]។ ម្ចាស់បណ្តឹងឧទ្ធរណ៍ក៏លើកឡើងថា បុព្វសិទ្ធិតាមផ្លូវតុលាការដែលអាចការពារករណីខ្វែងយោបល់គ្នា នៅខែ មេសា ឆ្នាំ ២០១៣ មិនដាច់ខាតទេ ហើយក៏មិនមានអាទិភាពជាងភាពចាំបាច់ក្នុងការការពារសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ដែរ[17]។ ចុងក្រោយ ម្ចាស់បណ្តឹងឧទ្ធរណ៍លើកទឡ្ហីករណ៍ថា ករណីខ្វែងយោបល់គ្នា នៅខែ មេសា ឆ្នាំ ២០១៣ ទំនងជាមានសារៈសំខាន់ដល់ការស៊ើបអង្កេត ដោយសារថា ករណីនេះបានលើកយោងនៅក្នុងដីកាសម្រេចចំនួនប្រាំដែលបានចេញនាពេលថ្មីៗនេះដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ហេតុនេះ ព័ត៌មានដែលស្នើសុំគឺជាព័ត៌មានចាំបាច់ដើម្បីការពារសិទ្ធិរបស់គាត់ក្នុងការរៀបចំការពារក្តី[18] និងសិទ្ធិស្មើគ្នាចំពោះមុខច្បាប់[19]។ ហេតុនេះ ម្ចាស់បណ្តឹងឧទ្ធរណ៍ស្នើសុំឱ្យអង្គជំនុំជម្រះ “ក. ទទួលយកបណ្តឹងឧទ្ធរណ៍នេះ ខ. ច្រានចោលដីកាសម្រេច

---

[14] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៧។

[15] *ដូចយោងខាងលើ* កថាខណ្ឌ ២៩ ដល់ ៣២។

[16] *ដូចយោងខាងលើ* កថាខណ្ឌ ៣៣។

[17] *ដូចយោងខាងលើ* កថាខណ្ឌ ៣៥ ដល់ ៣៨។

[18] *ដូចយោងខាងលើ* កថាខណ្ឌ ៤១។

[19] *ដូចយោងខាងលើ* កថាខណ្ឌ ៤៣។

ដែលរងការជំទាស់ គ. ស្រាយបំភ្លឺដំណើរខ្វែងយោបល់គ្នា អនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង ដោយពិចារណាទៅលើលក្ខខណ្ឌតម្រូវនៃការសហការគ្នាផ្អែកតាមច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និង ឃ. បង្គាប់ដល់សហចៅក្រមស៊ើបអង្កេត ឱ្យផ្តល់ដល់ [redacted] នូវព័ត៌មានដែលបានស្នើសុំ ទាក់ទិននឹងករណីខ្វែងយោបល់គ្នា នៅខែ មេសា ឆ្នាំ ២០១៣"[20]។

៦. សហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនបានដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ទេ។

## II. ភាពទទួលយកបាន

៧. ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានអះអាងថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលបានតាមវិធាន ៧៣ ឬ ៧៤ នៃវិធានផ្ទៃក្នុង ដែលចែងពីយុត្តាធិការជាក់លាក់របស់អង្គបុរេជំនុំជម្រះ ប៉ុន្តែលើកទឡ្ហីករណ៍ថា អង្គបុរេជំនុំជម្រះគួរប្រកាសថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន តាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដើម្បីការពារសិទ្ធិរបស់គាត់ក្នុងការទទួលបានការកាត់ក្តីដោយតុលាការមួយដែលត្រូវបានបង្កើតឡើងដោយច្បាប់ រៀបចំការការពារក្តី និងមានភាពស្មើគ្នាចំពោះមុខច្បាប់[21]។ វិធាននេះចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

> ***<u>វិធាន ២១៖ គោលការណ៍ជាសារវ័ន្ត</u>***
>
> ១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង។

៨. អង្គបុរេជំនុំជម្រះធ្លាប់បានសម្រេចថា គោលការណ៍ជាសារវ័ន្តដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលឆ្លុះបញ្ចាំងនូវលក្ខខណ្ឌតម្រូវនៃសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ដែលថា អ.វ.ត.ក ជាប់កាតព្វកិច្ចក្នុងការអនុវត្ត អនុលោមតាមវិធាន ១៣(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា[22] មាត្រា៣៥*ថ្មី* នៃច្បាប់ស្តីពីការបង្កើត

---

[20] *ដូចយោងខាងលើ* កថាខណ្ឌ ៤៤។

[21] *ដូចយោងខាងលើ* កថាខណ្ឌ ២៦ ដល់ ២៧។

[22] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង")។

អ.វ.ត.ក[23] និងមាត្រា ១៤(៣) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[24] អាចធានាថា តុលាការនេះអនុម័តយកការបកស្រាយបែបទូលាយនូវសិទ្ធិប្តឹងឧទ្ធរណ៍ ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីមានភាពយុត្តិធម៌ និងតាមគោលការណ៍ចំពោះមុខ ហើយរក្សាបាននូវតុល្យភាពនៃសិទ្ធិរបស់ភាគីទាំងឡាយ[25]។ នៅពេលមានតម្រូវការអង្គហេតុ និងកាលៈទេសៈពិសេសនៃរឿងក្តី អង្គបុរេជំនុំជម្រះបានទទួលយកបណ្តឹងឧទ្ធរណ៍ដែលលើកឡើងនូវបញ្ហានៃសិទ្ធិជាសារវ័ន្ត ឬ “បញ្ហាធ្ងន់ធ្ងរនៃភាពយុត្តិធម៌” អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង[26]។ នៅពេលលើកឡើងត្រង់ចំណុចនេះ វិធាន ២១ នៃវិធានផ្ទៃក្នុងមិនបានផ្តល់ការអនុញ្ញាតឲ្យប្តឹងឧទ្ធរណ៍ដោយស្វ័យប្រវត្តិ ដែលលើកឡើងនូវទឡ្ហីករណ៍នានាដោយផ្អែកលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ទេ។ ដើម្បីឲ្យអង្គបុរេជំនុំជម្រះអនុវត្តនូវយុត្តាធិការលើបណ្តឹងឧទ្ធរណ៍ទៅតាមវិធានដែលបានលើកឡើងនោះ ម្ចាស់បណ្តឹងឧទ្ធរណ៍ចាំបាច់ត្រូវបង្ហាញថា ក្នុងកាលៈទេសៈពិសេសនៃរឿងក្តី

---

[23] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (“ច្បាប់ អ.វ.ត.ក”)។

[24] *សូមមើល ឧទាហរណ៍* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (“សំណុំរឿង ០០២”) (អបជ ៦៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូ នៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ A371/2/12 កថាខណ្ឌ ១៣ ដល់ ១៨ កថាខណ្ឌ ២៧។

[25] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០២ (អបជ ១១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និង កាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឯកសារ A190/I/20 កថាខណ្ឌ ៣៦។ សំណុំរឿង ០០២ (អបជ ៧១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D390/1/2/4 (“សាលដីកាលើចម្លើយតបរបស់ អៀង សារី”) កថាខណ្ឌ ១៣។ សំណុំរឿង ០០២ (អបជ ១៤) សេចក្តីសម្រេចលើសេចក្តីជូនដំណឹងរបស់មេធាវីការពារក្តីអំពីកំហុសក្នុងការបកប្រែភាសា ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១០ ឯកសារលេខ ២ (“សេចក្តីសម្រេចលើកំហុសក្នុងការបកប្រែភាសា”) កថាខណ្ឌ ៣។ សំណុំរឿង ០០២ (អបជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 (“សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ”) កថាខណ្ឌ ៤៩។

[26] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០២ (អបជ ៤២) ដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំព្យួរកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1) ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១២ ឯកសារ D264/2/6 កថាខណ្ឌ ១៣ ដល់ ១៤។ សាលដីកាលើចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ១៣ *និង* សេចក្តីសម្រេចលើកំហុសក្នុងការបកប្រែភាសា កថាខណ្ឌ ២ ដល់ ៦។

ដែលបានលើកឡើង អន្តរាគមន៍របស់អង្គបុរេជំនុំជម្រះជាការចាំបាច់ ដើម្បីរារាំងមិនឱ្យមានព្យសនកម្មដែលមិនអាចជួសជុលបានចំពោះភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ អង្គបុរេជំនុំជម្រះបានសង្កត់ធ្ងន់ថា វិធាន ២១ នៃវិធានផ្ទៃក្នុង មិនបានអនុញ្ញាតឱ្យខ្លួនដោះស្រាយបញ្ហាជាសម្មតិកម្ម ឬផ្តល់មតិយោបល់ណែនាំនោះទេ[27]។

៩. ចាប់ពីដំបូងមក អង្គបុរេជំនុំជម្រះយល់ថា អង្គជំនុំជម្រះពុំមានយុត្តាធិការក្នុងការទទួលយកសំណើរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលសុំការបកស្រាយបំភ្លឺពីដំណើរការខ្វែងយោបល់គ្នា តាមវិធាន ៧២ នៃវិធានផ្ទៃក្នុងទេ។ ម្ចាស់បណ្តឹងឧទ្ធរណ៍ជំទាស់នឹងការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើវិធាន ៧២ នៃវិធានផ្ទៃក្នុង ដែលនឹងអនុញ្ញាតឱ្យមានករណីខ្វែងយោបល់គ្នាគ្រប់ដណ្តប់ទៅលើសេចក្តីសម្រេចនាពេលអនាគតដែលពាក់ព័ន្ធនឹងបញ្ហាស្រដៀងគ្នា ឬបញ្ហាពាក់ព័ន្ធ[28]។ ម្ចាស់បណ្តឹងឧទ្ធរណ៍អះអាងថា ការបកស្រាយនេះមិនស៊ីសង្វាក់គ្នាទៅនឹងកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការសហការគ្នា និងការពិភាក្សាសម្រេចទៅលើសារណានានាដែលបានដាក់ដោយភាគី ឬអ្នកចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ដែលនាំឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍មិនត្រូវបានស៊ើបអង្កេតដោយតុលាការដែលបង្កើតឡើងដោយច្បាប់[29]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះច្រានចោល ឬមោឃៈសេចក្តីសម្រេចជាក់លាក់ដែលនីតិវិធីនេះត្រូវបានយកទៅអនុវត្តនោះទេ (*ឧទាហរណ៍* ដីកាសម្រេចចំនួនបួន) តែបែរជា

---

[27] *សូមមើល ឧទាហរណ៍* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ១៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ជំទាស់ទៅនឹងការបំភ្លឺរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីសុពលភាពនៃដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ D212/1/2/2 កថាខណ្ឌ ៦។ សំណុំរឿង ០០៤ ("អបជ ១១") សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D205/1/1/2 កថាខណ្ឌ ៨។ សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ១០) សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសារណារបស់ [redacted] ចំនួនដប់បួនច្បាប់ដែលបានដាក់ទៅ [ការិយាល័យសហចៅក្រមស៊ើបអង្កេត] ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D87/2/2 កថាខណ្ឌ ២៦។ សំណុំរឿង ០០២ (អបជ ៦០) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១០ ឯកសារD345/5/11 កថាខណ្ឌ ១១។

[28] *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៩។

[29] *ដូចយោងខាងលើ* កថាខណ្ឌ ៣២។

ស្នើសុំមតិយោបល់ណែនាំពីអង្គបុរេជំនុំជម្រះ ស្តីពីនិត្យានុកូលភាពនៃនីតិវិធីទៅវិញ។ ទោះបីសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជាក់ថា វាជាការសមរម្យដែលត្រូវពន្យល់ពីការយល់ឃើញរបស់ខ្លួនលើវិធាន ៧២ នៃវិធានផ្ទៃក្នុង ដើម្បីលុបបំបាត់នូវមន្ទិលសង្ស័យរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍អំពីកង្វះការសហការណ៍ជាមួយសមភាគីជាតិរបស់គាត់ក៏ដោយ ក៏អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ការជំទាស់របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ទៅនឹងការបកស្រាយនេះ ដែលត្រូវបានបង្កើតឡើងតាមន័យពាក្យពេចន៍ទូទៅ មិនស្ថិតក្នុងបញ្ញត្តិរបស់វិធាន ២១ នៃវិធានផ្ទៃក្នុងទេ។

១០. ចំពោះសំណើរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលស្នើសុំព័ត៌មានអំពីករណីខ្វែងយោបល់គ្នា នៅខែមេសា ឆ្នាំ ២០១៣ វិញ អង្គបុរេជំនុំជម្រះរម្លឹកឡើងវិញថា អនុលោមតាមវិធាន ៧២(១) នៃវិធានផ្ទៃក្នុង ការខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេតគឺជាកិច្ចការផ្ទៃក្នុងរបស់ការិយាល័យរបស់ពួកគេ ហើយហេតុនេះ វាជាការសម្ងាត់ លុះត្រាតែពួកគេលើកយកមកដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះដើម្បីដោះស្រាយ។ អនុលោមតាម វិធាន ៧២(២) នៃវិធានផ្ទៃក្នុង កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃអង្គហេតុ និងសំអាងហេតុនៃការខ្វែងយោបល់គ្នាមិនត្រូវដាក់នៅក្នុងសំណុំរឿងនៃការស៊ើបអង្កេតទេ លើកលែងតែការខ្វែងយោបល់គ្នានោះត្រូវបានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះដើម្បីដោះស្រាយ ហើយវាពាក់ព័ន្ធនឹងសេចក្តីសម្រេច ប្រឆាំងនឹងភាគីណាមួយនៃកិច្ចដំណើរការនីតិវិធីដែលមានសិទ្ធិប្តឹងឧទ្ធរណ៍។ ការពិចារណាជាមូលដ្ឋានសម្រាប់ការដកកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការខ្វែងយោបល់គ្នាចេញពីសំណុំរឿងគឺថា កំណត់ហេតុទាំងនោះបង្កើតជាផ្នែកនៃការពិភាក្សាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត។ អនុលោមតាមវិធាននានាដែលត្រូវបានបង្កើតឡើងនៅកម្រិតអន្តរជាតិ "ការពិភាក្សាសម្រេច[តាមផ្លូវតុលាការ] ជាកិច្ចការសម្ងាត់"[30] ហើយ ហេតុនេះ "ឯកសារផ្ទៃក្នុងរបស់ចៅក្រមដែលត្រូវបានការពារដោយភាពសម្ងាត់

---

[30] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Šešelj* សំណុំរឿងលេខ IT-03-67-T សេចក្តីសម្រេចបើករបាយការណ៍របស់ចៅក្រមប្រធានអង្គជំនុំជម្រះ ផ្ញើជូនប្រធានតុលាការ ឬ ជាជម្រើសម្យ៉ាងទៀត ចៅក្រមដែលគាត់បានចាត់តាំង ពាក់ព័ន្ធនឹងញត្តិប្តឹងជំទាស់ចៅក្រម Harhoff ជាចៅក្រមប្រធានអង្គជំនុំជម្រះសាលាដំបូង III ចុះថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៣ ទំព័រ ៣ (ភាសាអង់គ្លេស)។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Prlić និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-04-74-T ដីការបស់ចៅក្រមប្រធានអង្គជំនុំជម្រះ ពាក់ព័ន្ធនឹងសំណើរបស់មេធាវីការពារក្តី Prlić ដែលស្នើសុំបញ្ចេញលិខិតទំនាក់ទំនង អង្គជំនុំជម្រះសាលាដំបូង III ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០១០ ("សេចក្តីសម្រេចលើសំណើសុំបញ្ចេញឯកសារ ក្នុង*រឿងក្តី Prlić*") ទំព័រ ២ (ភាសាអង់គ្លេស)។ *សូមមើល ឧទាហរណ៍* ក្រមសីលធម៌ចៅក្រមនៃតុលាការ ICC ឯកសារ ICC-BD/02-01-05 មាត្រា ៦ ("ចៅក្រមត្រូវគោរពភាពសម្ងាត់នៃការប្រឹក្សាយោបល់ដែលពាក់ព័ន្ធនឹងមុខងារតុលាការរបស់ពួកគេ និងការសម្ងាត់នៃការពិភាក្សាសម្រេច")។ វិធានស្តីពីនីតិវិធី និងកស្តុតាងនៅតុលាការ ICC ឯកសារ ICC-PIDS-LT-02-002/13 វិធាន ៥(១)(ក) (ដែលចែងពីសម្បថចូលកាន់

នៃការពិភាក្សាសម្រេច ឬភាពជាសម្ងាត់នៃកិច្ចឆ្លើយឆ្លងគ្នា មិនមានបំណងបញ្ចេញដោយស្វ័យប្រវត្តិដល់ភាគីទីបីទេ"[31]។ ហេតុនេះ ការផ្ដល់ព័ត៌មានដែលទាក់ទិននឹងករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេតត្រូវស្ថិតក្នុងរង្វង់ឆន្ទានុសិទ្ធិរបស់ពួកគេជាដាច់ខាត។ អង្គបុរេជំនុំជម្រះមិនត្រូវជ្រៀតជ្រែកចូលក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិនេះទេ លុះត្រាតែមានការចង្អុលបង្ហាញថា ក្នុងកាលៈទេសៈពិសេសនៃរឿងក្ដី ការបញ្ចេញព័ត៌មានអំពីការខ្វែងយោបល់គ្នាគឺជាការចាំបាច់ ដើម្បីការពារសិទ្ធិរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌។

១១. អង្គបុរេជំនុំជម្រះយល់ថា ម្ចាស់បណ្ដឹងឧទ្ធរណ៍មិនបានបង្ហាញថា ការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតមិនផ្ដល់ឲ្យខ្លួននូវព័ត៌មានដែលបានស្នើសុំអំពីករណីខ្វែងយោបល់គ្នា នៅខែ មេសា ឆ្នាំ ២០១៣ ធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់គាត់ក្នុងការទទួលបានការកាត់ក្ដីដោយតុលាការដែលត្រូវបានបង្កើតឡើងដោយច្បាប់ទេ។ មានការដឹងច្បាស់ថា ដីកាសម្រេចនីមួយៗក្នុងចំណោមដីកាសម្រេចទាំងបួនត្រូវបានចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្នាក់ ហើយថា សហចៅក្រមស៊ើបអង្កេតជាតិដែលជាអ្នកបានទទួលញត្តិរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ដែរនោះ បានជ្រើសរើសមិនឆ្លើយតបទៅនឹងញត្តិទាំងនោះ យ៉ាងហោចណាស់នៅក្នុងដំណាក់កាលនេះ។ ពាក់ព័ន្ធនឹងបញ្ហានេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកត់សម្គាល់ នៅក្នុងដីកាសម្រេចនីមួយៗរបស់ខ្លួនរួចហើយថា កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការខ្វែងយោបល់គ្នាត្រូវបានចុះបញ្ជីពីមុន ហើយបានពន្យល់នៅក្នុងដីកាសម្រេចដែលរងការជំទាស់ថា គ្មានការសហការណ៍គ្នា ដែលផ្ទុយពីអំណះអំណាងរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ ដោយសារថា "ការខ្វែងយោបល់គ្នាលើបញ្ហាជាក់លាក់ណាមួយអាចអនុវត្តទៅលើសេចក្ដីសម្រេចនាពេលអនាគតដែលពាក់ព័ន្ធបញ្ហាដូចគ្នា ឬបញ្ហាពាក់ព័ន្ធ"[32]។ សហចៅក្រមស៊ើបអង្កេតជាតិមិនបានជំទាស់ទៅនឹងដំណើរការនេះ ឬមិនបានបង្ហាញនូវទស្សនៈផ្ទុយទេ។ វិធានចែងថា សហចៅក្រមស៊ើបអង្កេតម្នាក់អាចបំពេញកិច្ចមានសុពលភាពតែម្នាក់ឯងបាន ប្រសិនបើលក្ខខណ្ឌតម្រូវនៃនីតិវិធីនៃការខ្វែងយោបល់គ្នាត្រូវបានបំពេញ[33]។ នៅក្នុងករណី

---

តំណែងរបស់ចៅក្រមថា៖ "ខ្ញុំនឹងគោរពដល់ភាពសម្ងាត់នៃការស៊ើបអង្កេត និងការកាត់ក្ដី និងការសម្ងាត់នៃការពិភាក្សាសម្រេច"។ វិធាន ៩៦ នៃវិធានផ្ទៃក្នុង (ដែលចែងថា អង្គជំនុំជម្រះសាលាដំបូងត្រូវពិភាក្សាគ្នា *"ដោយសម្ងាត់"*)។

[31] សេចក្ដីសម្រេចលើសំណើសុំបញ្ចេញឯកសារ ក្នុង*រឿងក្ដី Prlić* ទំព័រ ២ (ភាសាអង់គ្លេស)។

[32] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៨។

[33] មាត្រា ៥(៤) នៃកិច្ចព្រមព្រៀង។ មាត្រា ២៣ថ្មី (២) នៃច្បាប់ អ.វ.ត.ក។ វិធាន ៧២(២) និង (៣) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* ការខ្វែងយោបល់គ្នា លេខ ០០១/១៨-១១-២០០៨-អវតក/អបជ ការពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩

នេះ វាមិនចាំបាច់ឱ្យមានការធានាថា រយៈពេលដោះស្រាយចំនួន ៣០ ថ្ងៃ បានកន្លងផុត មុនពេលដែលសហចៅក្រមស៊ើបអង្កេតជាតិអាចសម្រេចទៅលើញត្តិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដោយសារ ពុំមានចំណុចណាមួយនៅក្នុងញត្តិទាំងនោះពាក់ព័ន្ធទៅនឹងសាច់រឿងនានាដែលមានរៀបរាប់ក្នុងកថាខណ្ឌ (ក) ដល់ (គ) នៃវិធាន ៧២(៣) នៃវិធានផ្ទៃក្នុងទេ[34]។ មុនពេលចេញដីកាសម្រេចទាំងបួន សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបានតម្រូវត្រឹមតែជូនដំណឹងដល់សមភាគីជាតិរបស់ខ្លួននូវដំណើរការនៃកិច្ចដែលបានស្នើឡើងប៉ុណ្ណោះ ដែលអនុញ្ញាតឱ្យគាត់បញ្ចេញទស្សនៈរបស់ខ្លួន ហើយគាត់អាចនាំយកការខ្វែងយោបល់គ្នានោះមកដោះស្រាយនៅចំពោះមុខអង្គបុរេជំនុំជម្រះបាន។ ទាក់ទិននឹងចំណុចនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ក្របខណ្ឌច្បាប់នៅ អ.វ.ត.ក ផ្តល់ឆន្ទានុសិទ្ធិទូលំទូលាយដល់សហចៅក្រមស៊ើបអង្កេត ពីរបៀបនៃការដោះស្រាយការខ្វែងយោបល់គ្នារបស់ពួកគេ និងការប្រាស្រ័យទាក់ទងការងារជាមួយគ្នា។ ការបញ្ចូលការខ្វែងយោបល់គ្នាទៅក្នុងកំណត់ហេតុជួយឱ្យបង្ហាញថា នីតិវិធីដែលមានចែងក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុង ត្រូវបានអនុវត្តតាម តែវាមិនមានលក្ខណៈចាប់បង្ខំទេ[35]។ ការពុំមានបង្ហាញអ្វីដែលផ្ទុយពីនេះធ្វើឱ្យគេអាចសន្មតបានថា ពាក់ព័ន្ធនឹងភារកិច្ចតាមផ្លូវតុលាការ និងក្រមសីលធម៌របស់ខ្លួន សហចៅក្រមស៊ើបអង្កេតធានាថា ពួកគេបំពេញកិច្ច អនុលោមតាមលក្ខខណ្ឌតម្រូវដែលមានចែងក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុង។ ពុំមានការចង្អុលបង្ហាញនៅក្នុងករណីនេះ ដែលបញ្ចេញឱ្យឃើញនូវកង្វះនៃការអនុវត្តតាមលក្ខខណ្ឌតម្រូវនានារបស់វិធាន ៧២ នៃវិធានផ្ទៃក្នុង ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការចេញដីកាសម្រេចចំនួនបួន ដែលចាំបាច់តម្រូវឱ្យមានអន្តរាគមន៍ពីអង្គបុរេជំនុំ

---

កថាខណ្ឌ ១៦ និង ២៧។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៧៤ ដល់ ២៧៦។ សំណុំរឿង ០០៤ សេចក្តីសម្រេចលើសំណើបន្ទាប់របស់ [redacted] សុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រីឱ្យមកបង្ហាញខ្លួនជាលើកដំបូង ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A122/6.1/3 កថាខណ្ឌ ១៤។

[34] ក្នុងករណីនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អង្គជំនុំជម្រះបានប្រានចោលបណ្តឹងឧទ្ធរណ៍របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចទាំងពីរ សេចក្តីសម្រេចលើសំណើសុំមោឃភាព និងសេចក្តីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ។ សូមមើល សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារលេខ D190/1/2 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធសំណើសុំមោឃភាព ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤ ឯកសារលេខ D185/1/1/2។ ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានប្តឹងឧទ្ធរណ៍នឹងសេចក្តីសម្រេចលើសំណើសុំពិចារណាឡើងវិញទេ ប៉ុន្តែហេតុផលដូចគ្នានឹងអនុវត្ត។

[35] *សូមមើល* មាត្រា ៥(៤) និង ៧(១) នៃកិច្ចព្រមព្រៀង។ មាត្រា ២៣ថ្មី(៣) នៃច្បាប់ អ.វ.ត.ក និង វិធាន ៧២(១) នៃវិធានផ្ទៃក្នុង។

ជម្រះ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដើម្បីពិចារណាបង្គាប់ឱ្យសហចៅក្រមស៊ើបអង្កេតបញ្ចេញព័ត៌មានអំពីការខ្វែងយោបល់គ្នារបស់ពួកគេទេ។

១២. ចុងក្រោយ អង្គបុរេជំនុំជម្រះយល់ថា ពុំមានខ្លឹមសារក្នុងទឡ្ហីករណ៍របស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ដែលថា ការបដិសេធមិនផ្ដល់ព័ត៌មានដែលបានស្នើសុំជាការរំលោភដល់សិទ្ធិរបស់គាត់ក្នុងការទទួលបានសមភាពចំពោះមុខច្បាប់ និងសិទ្ធិរៀបចំការពារក្ដីទេ។ ដូចដែលបានរម្លឹកឡើងខាងលើរួចមកហើយ ការខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេតជាការសម្ងាត់ មិនត្រឹមតែចំពោះម្ចាស់បណ្ដឹងឧទ្ធរណ៍ប៉ុណ្ណោះទេ តែវាជាវិធានមួយ។ ហេតុនេះ ពុំមានភាពខុសគ្នាក្នុងការប្រព្រឹត្តទេ ហើយក៏ពុំមានសិទ្ធិស្វ័យប្រវត្តិក្នុងការចូលពិនិត្យមើលករណីខ្វែងយោបល់គ្នា ដែលផ្ដើមចេញពីសិទ្ធិក្នុងការរៀបចំការការពារក្ដីដែរ។ ម្ចាស់បណ្ដឹងឧទ្ធរណ៍ប៉ាន់ស្មានអំពីខ្លឹមសារនៃករណីខ្វែងយោបល់គ្នា នៅខែ មេសា ឆ្នាំ ២០១៣ តែមិនបានបង្ហាញឱ្យច្បាស់ថា តើកង្វះនៃការពិនិត្យមើលព័ត៌មានដែលបានស្នើសុំ នឹងប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិទទួលបានពេលវេលា និងសម្ភារៈគ្រប់គ្រាន់ក្នុងការរៀបចំការពារក្ដីនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីដោយរបៀបណាទេ[36]។ ទាក់ទិននឹងបញ្ហានេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ម្ចាស់បណ្ដឹងឧទ្ធរណ៍មានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ តែមិនទាន់ត្រូវបានចោទប្រកាន់ជាផ្លូវការទេ។ ដីកាសម្រេចចំនួនបួនបដិសេធសំណើចំនួនប្រាំដែលគាត់បានដាក់ដោយផ្អែកលើមូលដ្ឋាននេះ។ ក្នុងនាមជាជនសង្ស័យ គាត់មិនមានសិទ្ធិអនុវត្តសិទ្ធិនានាដែលចែងសម្រាប់ជនត្រូវចោទ តាមវិធានផ្ទៃក្នុងទេ[37]។ ម្ចាស់បណ្ដឹងឧទ្ធរណ៍មិន

[36] *សូមមើល* បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៤១។

[37] *សូមមើល* ដីកាសម្រេចបឋមលើសំណើពិចារណាឡើងវិញ កថាខណ្ឌ ១៤, ១៦ ("សហចៅក្រមស៊ើបអង្កេតអន្តរជាតិកត់សម្គាល់ថា នៅក្នុងការពិចារណាឡើងវិញលើការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ បញ្ហាសំខាន់គឺថា តើជនសង្ស័យគឺជាជនត្រូវចោទ ឬអត់ បើមិនអញ្ចឹងទេ គួរតែចាត់ទុកថាត្រូវប្រឈមនឹងបទចោទព្រហ្មទណ្ឌ ឬអត់។ [...] ទោះជាយ៉ាងណាក្ដី ដើម្បីធានាឱ្យមានការគោរពពេញលេញអំពីគោលការណ៍ស្ដីពីសច្ចភាពផ្លូវច្បាប់ និងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា ជាការសមស្របដែលត្រូវធ្វើការអញ្ជើញ ជាពិសេសស្នើឱ្យក្រុមមេធាវីការពារក្ដីជនសង្ស័យ បង្ហាញថាតើសារណាដែលមាននៅក្នុងញត្តិរបស់ខ្លួននឹងធ្វើឡើង ប្រសិនបើខ្លួនបានឱកាសឱ្យបង្ហាញយោបល់នៅក្នុងរយៈពេលសមស្រប ឬថាតើខ្លួនមានបំណងដាក់សារណាបន្ថែមទៀតដែរឬអត់ ដើម្បីគាំទ្រសំណើរបស់ខ្លួនស្នើសុំឱ្យពិចារណាឡើងវិញលើសេចក្ដីសម្រេចសំណុំរឿង")។ ដីកាសម្រេចលើសំណើពិចារណាឡើងវិញ កថាខណ្ឌ ២៥ ("ចៅក្រមស៊ើបអង្កេតអន្តរជាតិបញ្ជាក់ឡើងវិញថា ប្រសិនបើជនសង្ស័យត្រូវបានចោទ ដោយអនុវត្តតាមវិធានផ្ទៃក្នុង នោះគាត់នឹងទទួលបានពេលវេលា និងសម្បទារូបវន្តគ្រប់គ្រាន់ដើម្បីរៀបចំការពារក្ដីរបស់ខ្លួន។ ទោះយ៉ាងណា នៅដំណាក់កាលនេះ ជនសង្ស័យមិនមែនជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធី មិនទាន់ជាប់ឃុំឃាំង គ្មានសំណុំរឿងដែលត្រូវឆ្លើយ ដូច្នេះក៏មិនមានភាពអយុត្តិធម៌ ឬផលប៉ះពាល់ដោយសារជនសង្ស័យមិនអាចចូលពិនិត្យមើលសំណុំរឿងដែរ)។ ដីកាសម្រេចលើសំណើសុំមោឃភាព កថាខណ្ឌ ៣៣

បានបង្ហាញថា នៅដំណាក់កាលនេះ ការអនុញ្ញាតឱ្យគាត់ចូលពិនិត្យមើលព័ត៌មានសម្ងាត់អំពីករណីខ្វែងយោបល់គ្នាទៅលើដីកាសម្រេចទាំងនេះ គឺជាការចាំបាច់ដើម្បីការពារខ្លួនគាត់ប្រឆាំងនឹងឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទេ។

១៣. ហេតុនេះ អង្គបុរេជំនុំជម្រះយល់ថា បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។

## III. សេចក្តីសម្រេច

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទថា៖**

**មិនទទួល**យកបណ្តឹងឧទ្ធរណ៍នេះទេ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

ភ្នំពេញថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Rowan DOWNING** **នំយ ថុល** **Chang-Ho CHUNG** **ហួត វុទ្ធី**

---

(“សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចថា ញត្តិមិនអាចទទួលយកបានតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុងទេ ពីព្រោះថា [redacted] មិនមែនជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធី ហើយសម្រេចថា វិធាន ២១(១) នៃវិធានផ្ទៃក្នុង ក៏មិនអនុញ្ញាតឱ្យ [redacted] មានមធ្យោបាយផ្សេងដើម្បីដាក់ញត្តិដែរ”)។ ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ កថាខណ្ឌ ៥ (“ជនសង្ស័យមិនមែនជាជនត្រូវចោទ ដូច្នេះ គាត់មិនមានសិទ្ធិដាក់សំណើសុំបំពេញកិច្ចស៊ើបសួរឡើយ។ ឋានៈរបស់គាត់ជាជនសង្ស័យ បានក្លាយជាកម្មវត្ថុនៃសេចក្តីសម្រេចផ្សេងៗនៅក្នុង*សេចក្តីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តី* [redacted] *សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ចេញថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ ហើយសេចក្តីសម្រេចនេះមិនត្រូវបានប្រានចោលឡើយនៅពេលដែលប្តឹងឧទ្ធរណ៍ និងជាកម្មវត្ថុនៃសេចក្តីសម្រេចផ្សេងៗនៅក្នុង*ដីកាសម្រេចលើសំណើពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់ក្រុមមេធាវីការពារក្តី* [redacted] *សុំពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ចេញថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពិចារណាឃើញថា ឥឡូវនេះ ឋានៈរបស់ជនសង្ស័យគឺមានលក្ខណៈច្បាស់លាស់ហើយ ដូច្នេះមិនចាំបាច់យកមកពិភាក្សាថែមទៀតហើយ”)។